## ៣.១២ កម្មវិធីអាហារូបករណ៍សំរាប់សិស្សក្រីក្រនៅមធ្យមសិក្សា

### វត្ថុបំណង និង យុត្តិកម្ម

វត្ថុបំណងជាយុទ្ធសាស្ត្ររយៈពេលវែងរបស់កម្មវិធីគឺបង្កើនការចូលរៀន ការឡើងថ្នាក់ និងកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្សក្រីក្រនៅក្នុងការអប់រំមធ្យមសិក្សា។ ប្រការនេះបានរួមចំណែកសំរេចបានចំណុចដៅ និង គោលដៅរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលរួមមានការបង្កើនការចូលរៀនមធ្យមសិក្សាបឋមភូមិ រហូតដល់ ១លាននាក់ និងមធ្យមសិក្សាទុតិយភូមិ ចំនួន ៣០០,០០០នាក់ នៅឆ្នាំ២០០៨។

យុទ្ធសាស្ត្ររបស់កម្មវិធីគឺ ទូទាត់តម្លៃផ្ទាល់នៃការចូលរៀននៅសាលាមធ្យមសិក្សា និង តម្លៃឱកាស ដែលទទួលបានរបស់គ្រួសារក្រីក្រ។ វត្ថុបំណងដែលសំខាន់គឺ ធានាការបង្កើនការចូលរួមរបស់សិស្សពូកែដែលជាកូនគ្រួសារក្រីក្រ និង ជួបការលំបាក ជាពិសេសកុមារី ព្រមទាំងជនជាតិភាគតិច តាមរយៈការបង្កើនចំនួនអាហារូបករណ៍ជាបន្តបន្ទាប់ចំពោះសិស្សក្រីក្រ។ វត្ថុបំណងទី២គឺ ពង្រឹងសមត្ថភាពរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ក្នុងការកសាងផែនការ និងពិនិត្យតាមដានអន្តរាគមន៍ និង កម្មវិធីនានា ព្រមទាំងការបែងចែកថវិកាសំរាប់ជួយសិស្សក្រីក្រ។ វត្ថុបំណងនៃការកសាងសមត្ថភាពមួយទៀតគឺ បង្កើនសមត្ថភាពសាលារៀន សហគមន៍ ក្នុងការកសាងផែនការប្រតិបត្តិ និង ការអនុវត្តកម្មវិធីអាហារូបករណ៍។

### វិសាលភាព និង ភាពគ្របដណ្តប់

ការជ្រើសរើសសាលារៀន ត្រូវផ្អែកលើសន្ទស្សន៍នៃភាពក្រីក្ររបស់កម្មវិធី WFP ដើម្បីកំណត់ឃុំ-សង្កាត់ក្រីក្របំផុត។ កម្មវិធីនេះបានអនុវត្ត នៅតាមសាលារៀនមធ្យមសិក្សាបឋមភូមិចំនួន២១៥ នៅក្នុង ខេត្ត-ក្រុងចំនួន១៧នាឆ្នាំសិក្សា២០០៣-០៤។ កម្មវិធីអាហារូបករណ៍នេះ ត្រូវពង្រីកទៅដល់មធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ២០០៥ ដោយគ្របដណ្តប់លើសាលាមធ្យមសិក្សាទុតិយភូមិគំរូ និង សាលាមធ្យមសិក្សាទុតិយភូមិមួយចំនួន នៅតាមជនបទ។ ក្រសួងអប់រំ យុវជន និង កីឡា នឹងពិនិត្យឡើងវិញពីលទ្ធភាពថវិកា ដើម្បីពង្រីកភាពគ្របដណ្តប់ ដោយបញ្ចូលអាហារូបករណ៍ដែលធ្លាប់បានទទួលពីអ្នកផ្តល់ជំនួយ ដូចជា JFPR, BETT ក្រោយពីគំរោងទាំងនេះត្រូវបានបញ្ចប់។

កម្មវិធីនេះ នឹងផ្តល់ប្រាក់លើកទឹកចិត្ត ចំពោះសិស្សអាហារូបករណ៍មួយចំនួន។ លក្ខណៈវិនិច្ឆ័យជ្រើសរើសសិស្សអាហារូបករណ៍ ថ្នាក់ទី៧-៩ នឹងបន្តផ្តោតទៅលើកុមារមកពីគ្រួសារក្រីក្របំផុត និង ក្រុមជនជួបការលំបាកផ្សេងៗទៀត ដែលរួមមានកុមារី និង ជនជាតិភាគតិច។ លក្ខណៈវិនិច្ឆ័យជ្រើសរើសសិស្សអាហារូបករណ៍ ថ្នាក់ទី១០-១២ ត្រូវផ្អែកលើលទ្ធផលប្រលងថ្នាក់ទី៩ ព្រមទាំងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសផ្សេងៗទៀត។ ការផ្តល់អាហារូបករណ៍មានកំរិតខុសគ្នារវាងសិស្សដែលបានចូលរៀនក្នុងសាលាគំរូ និង សាលាមធ្យមសិក្សានៅ

ជនបទ។  ដើម្បីសំរេចបានសមធម៌យេនឌ័រក្នុងការអប់រំមធ្យមសិក្សា សិស្សស្រីត្រូវមានចំនួនជាអប្បបរមា ៦០% នៃចំនួនសិស្សអាហារូបករណ៍ទាំងអស់នៅក្នុងសាលាដែលបានជ្រើសរើស។

ស្របតាមលក្ខណៈវិនិច្ឆ័យ និងការបែងចែកថវិកាដែលបានព្រមព្រៀង សាលារៀន សហគមន៍ និងក្រុមប្រឹក្សាភូមិ ជាអ្នកជ្រើសរើសចុងក្រោយ។ កម្មវិធីនេះផ្សារភ្ជាប់ទៅនឹងការពង្រីកសេវាអប់រំមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ព្រមទាំងកម្មវិធីវិនិយោគដល់សាលារៀនគំរូផងដែរ។

## សង្ខេបសកម្មភាពសំខាន់ៗ

សកម្មភាពសំខាន់ៗ រួមមាន

១. *អាហារូបករណ៍សំរាប់មធ្យមសិក្សាបឋមភូមិ* ផ្តល់ប្រាក់លើកទឹកចិត្តទៅឱ្យសិស្សក្រីក្របំផុតនៅថ្នាក់ទី ៧-៩ ជាពិសេសសិស្សស្រី និងក្រុមជនជួបការលំបាក។

២. *អាហារូបករណ៍សំរាប់មធ្យមសិក្សាទុតិយភូមិ* : ផ្តល់អាហាររូបករណ៍ដល់សិស្សពូកែ និងផ្អែកលើសន្ទស្សន៍ភាពក្រីក្រ ដែលបានចូលរៀននៅសាលារៀនគំរូ និងមធ្យមសិក្សាទុតិយភូមិនៅជនបទ និងផ្តល់អាហារូបករណ៍កំរិតខ្ពស់ សំរាប់សិស្សដែលរៀនក្នុងសាលារៀនគំរូ។

៣. *ផ្តល់ថវិកាប្រតិបត្តិដល់គណៈកម្មការសាលារៀន* ផ្តល់ថវិកាប្រតិបត្តិសំរាប់គណៈកម្មការគ្រប់គ្រងនៅមូលដ្ឋាន ដើម្បីធ្វើផែនការ អនុវត្តការងារ និងពិនិត្យតាមដានកម្មវិធីអាហារូបករណ៍ នៅកំរិតសាលារៀន-សហគមន៍ ។

៤. *ការគ្រប់គ្រង និងពិនិត្យតាមដាន* កសាងសមត្ថភាពអ្នកគ្រប់គ្រង និងមន្ត្រីផែនការនៅរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ស្តីពីការបែងចែកថវិកា និងកសាងផែនការកម្មវិធី សំដៅជួយដល់គ្រួសារក្រីក្រ។ សកម្មភាពនេះ ក៏ជួយពង្រឹងសមត្ថភាពផ្នែកស្រាវជ្រាវ ប្រតិបត្តិ ការពិនិត្យតាមដាននិងការវាយតម្លៃ ដើម្បីវាយតម្លៃផលប៉ះពាល់របស់កម្មវិធីនេះទៅលើភាពក្រីក្រ ។

## ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

ការគ្រប់គ្រងកម្មវិធី មានលក្ខណៈវិមជ្ឈការខ្ពស់ ជាមួយសហគមន៍ និងសាលារៀនដោយបានបង្ហាញច្បាស់ពីភាពទទួលខុសត្រូវ លើការងារគ្រប់គ្រងសំខាន់ៗ។ នៅក្នុងរយៈពេលខ្លី  អគ្គនាយកដ្ឋានអប់រំ នឹងប្រគល់ភារកិច្ចដល់អង្គភាពគ្រប់គ្រងថវិកាថ្នាក់កណ្តាលអោយទទួលខុសត្រូវលើការកសាងផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រ ការគ្រប់គ្រង និងកិច្ចបញ្ជិការគណនេយ្យ។ លើសពីនេះទៀត អង្គភាពគ្រប់គ្រងថវិកាថ្នាក់កណ្តាលទទួលខុសត្រូវលើៈ ១) ការរៀបចំលក្ខណៈវិនិច្ឆ័យ និងភាពគ្របដណ្តប់របស់កម្មវិធី ដោយប្រើប្រាស់តួលេខ EMIS និងរបស់ការអង្កេតលើភាពក្រីក្រដទៃទៀត។  ២) ការរៀបចំសេចក្តីណែនាំអនុវត្តជាក់ស្តែង និង បែងចែកថវិកា

ដល់សាលារៀន និងខេត្ត-ក្រុង ៣) ការពិនិត្យតាមដានការរីកចំរើនរបស់កម្មវិធីទាំងមូល និងការវាយតម្លៃផលប៉ះពាល់។

មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង នឹងរៀបចំក្រុមការងារគ្រប់គ្រងអាហារូបករណ៍ សំរាប់ធ្វើការគ្រប់គ្រង និងពិនិត្យតាមដាន ព្រមទាំងផ្តល់ការជួយឧបត្ថម្ភផ្នែកបច្ចេកទេសដល់សាលារៀន និងសហគមន៍។ នៅកំរិតសាលារៀន និងសហគមន៍ គណៈកម្មការគ្រប់គ្រងមូលដ្ឋានដែលដឹកនាំដោយនាយកសាលារៀនត្រូវបានរៀបចំដើម្បីអនុវត្តការងារប្រចាំថ្ងៃរបស់កម្មវិធី។ គណៈកម្មការគ្រប់គ្រងមូលដ្ឋានទទួលខុសត្រូវលើការងារជ្រើសរើសសិស្ស ការបើកផ្តល់ប្រាក់អាហារូបករណ៍ ការពិនិត្យតាមដានការរីកចំរើន ការគ្រប់គ្រងថវិកា និងកិច្ចបញ្ជិការគណនេយ្យ។ អគ្គនាយកដ្ឋានអប់រំនឹងរៀបចំគំរូតារាងសវនកម្មផ្នែកបច្ចេកទេស ដោយមានការចូលរួមពីក្រុមការងារបញ្ញាបយេនឌ័រ ហើយអគ្គាធិការដ្ឋាននឹងរៀបចំគំរូតារាងសវនកម្មផ្ទៃក្នុងផ្នែកហិរញ្ញវត្ថុ។

## ផែនការហិរញ្ញវត្ថុ

ការធ្វើផែនការហិរញ្ញវត្ថុផ្តោតសំខាន់ ទៅលើថវិកាចរន្តរបស់កម្មវិធីអាហារូបករណ៍។ មូលនិធិបន្ថែមផ្សេងៗទៀត ដែលបានមកពីអ្នកផ្តល់ជំនួយនានា ដូចជា (JFPR , BETT) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិកាមូលធន ប៉ុន្តែត្រូវគ្រប់គ្រងតាមរយៈការអនុវត្តការងារគ្រប់គ្រងរបស់ក្រសួងនៅក្នុងអគ្គនាយកដ្ឋានអប់រំដដែល។ ការកំណត់តម្លៃចាប់ពីឆ្នាំ២០០៤ទៅមុខនោះ គឺជាការអនុវត្តបន្តពីឆ្នាំ២០០៣ ក្នុងការផ្តល់ថវិកាដូចពេលមុនដែរ។

*តារាងទី១៣ :ផែនការហិរញ្ញវត្ថុសំរាប់ការលើកទឹកចិត្ត/អាហារូបករណ៍សំរាប់សិស្សក្រីក្រនៅមធ្យមសិក្សា*

| សកម្មភាព | ចំណាយ( គិតជា លានរៀល) | | | | |
|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2008 |
| ១- ការលើកទឹកចិត្តអាហារូបករណ៍នៅម.បឋមភូមិ | 2500 | 2,900 | 4,000 | 4,000 | 4,000 |
| ២- ការលើកទឹកចិត្តអាហារូបករណ៍ ម.ទុតិយភូមិ | 0 | 0 | 600 | 2,200 | 4,500 |
| ៣- ការអនុវត្តការងាររបស់គណៈកម្មការ ដឹកនាំសាលារៀន | 150 | 200 | 200 | 200 | 200 |
| ៤-ការងារគ្រប់គ្រង និងពិនិត្យតាមដាន | 150 | 200 | 200 | 200 | 200 |
| **ធនធាន :សរុប** | 2,800 | 3,300 | 5,000 | 6,600 | 8,900 |